# សេចក្តីប្រកាសរបស់ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន
# ប្រធានគណៈកម្មាធិការបេតិកភណ្ឌពិភពលោក
# និងជាឧបនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
**(រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១២)**

កាលពី២០ឆ្នាំមុន ពោលឲ្យចំគឺនាថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩២ នៅទីក្រុង Santa Fè សហរដ្ឋអាមេរិក គណៈកម្មាធិការបេតិកភណ្ឌពិភពលោក ក្នុងកិច្ចប្រជុំលើកទី១៦ បានសម្រេចចុះរមណីយដ្ឋានអង្គរក្នុងបញ្ជីបេតិកភណ្ឌពិភពលោក (របស់អង្គការយូណេស្កូ)។

សេចក្តីសម្រេចនេះមានលក្ខណៈថ្មីពុំធ្លាប់មានពីមុនមក និងប្រកបដោយភាពក្លាហានសម្រាប់សម័យនោះ សម្តែងឲ្យឃើញយ៉ាងច្បាស់នូវក្តីកង្វល់របស់សហគមន៍អន្តរជាតិចង់ធ្វើសហប្រតិបត្តិការជាមួយប្រទេសកម្ពុជាដោយប្រសិទ្ធភាពនិងឆាប់រហ័ស ដើម្បីដោះស្រាយបញ្ហាបន្ទាន់ក្នុងការអភិរក្សដែលកំពុងតែចោទចំពោះប្រាសាទទាំងឡាយ នៅក្នុងតំបន់បុរាណវិទ្យាដែលមានផ្ទៃដី ៤០.០០០ ហិកតាលាតសន្ធឹងនៅចន្លោះតំបន់រលួសនៅខាងត្បូង និងតំបន់បន្ទាយស្រីនៅខាងជើង។

តាំងពីពេលនោះមក សកម្មភាពអន្តរជាតិដែលធ្វើបន្តជាប់ឥតដាច់និងមានទ្រង់ទ្រាយធំ បានដំណើរការក្រោមការឧបត្ថម្ភគាំទ្ររបស់អង្គការយូណេស្កូ និងដោយមានប្រទេសបារាំង និងជប៉ុន ធ្វើជាសហប្រធាន។ សព្វថ្ងៃប្រទេសចំនួន១៦ មកពីទ្វីបទាំង៤ មានក្រុមប្រតិបត្តិករ ចំនួន៣៦ក្រុម កំពុងអនុវត្តគម្រោងចំនួន៦៤ ដែលប្រើប្រាស់ថវិកា២៥០លានដុល្លារអាមេរិក។

សាធារណមតិជាតិនិងអន្តរជាតិមូលមតិគ្នាវាយតម្លៃថា សមិទ្ធផលដែលបានកសាងកន្លងមកគឺវិសេសវិសាលណាស់។ មុនឆ្នាំ១៩៩៣ ដែលប្រារព្ធសន្និសីទអន្តរជាតិស្តីពីអង្គរ នាទីក្រុងតូក្យូនិងការបង្កើតគណៈកម្មាធិការសម្របសម្រួលកិច្ចគាំពារ និងអភិវឌ្ឍន៍តំបន់ប្រវត្តិសាស្ត្រអង្គរ (C.I.C.) រមណីយដ្ឋានអង្គរប្រកបទៅដោយគ្រាប់មីន ហើយប្រាង្គប្រាសាទស្ថិតក្នុងស្ថានភាពប្រឈមនឹងគ្រោះថ្នាក់។ ការជួញដូរខុសច្បាប់និងការលួចសម្បត្តិវប្បធម៌ប្រព្រឹត្ត ទៅហាក់ដូចជាមិនញញើតសមត្ថកិច្ចបន្តិចឡើយ។ ប្រជាពលរដ្ឋតាមភូមិឃុំនានាក្នុងរមណីយដ្ឋានអង្គរភាគច្រើនមានជីវភាពក្រីក្រ។

តាំងពីឆ្នាំ១៩៩៣មក រមណីយដ្ឋានអង្គរចាប់ផ្តើមរស់ឡើងវិញយ៉ាងពេញទំហឹង។ បន្ទាប់ពីសន្និសីទអន្តរជាតិក្រុង Paris ឆ្នាំ២០០៣ សកម្មភាពអភិរក្សត្រូវបានបំពេញបន្ថែម ដោយគម្រោងលើកតម្លៃវប្បធម៌ អភិវឌ្ឍន៍សេដ្ឋកិច្ច និងការប្រយុទ្ធប្រឆាំងភាពក្រីក្រ។

ដើម្បីជាសក្ខីភាពនៃការវាយតម្លៃខ្ពស់ចំពោះសកម្មភាពរបស់រាជរដ្ឋាភិបាលកម្ពុជាដែលមានសហគមន៍អន្តរជាតិជាដៃគូផ្នែកវិទ្យាសាស្ត្រ បច្ចេកទេស និងហិរញ្ញវត្ថុ **គណៈកម្មាធិការបេតិកភណ្ឌពិភពលោកបានសម្រេចចិត្តនឹងប្រារព្ធកិច្ចប្រជុំលើកទី៣៧ របស់ខ្លួននាខែមិថុនា ឆ្នាំ២០១៣ នៅរាជធានីភ្នំពេញ និងរមណីយដ្ឋានអង្គរ។**

នេះជាគំរូមួយបញ្ជាក់ឲ្យឃើញយ៉ាងច្បាស់នូវជោគជ័យនៃអនុសញ្ញាស្តីពីកិច្ចការពារបេតិកភណ្ឌពិភពលោកផ្នែកវប្បធម៌ និងធម្មជាតិ ក្នុងរយៈពេល៤០ឆ្នាំនៃអាយុរបស់ខ្លួន (១៩៧២-២០១២)។